00658963

E50/2/1/1/3

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**<u>ព័ត៌មានពិស្តារអំពីការដាក់ឯកសារ</u>**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ: សហមេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៥ ខែ មេសា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងចម្លើយរបស់សហព្រះរាជអាជ្ញាចំពោះបណ្តឹងសាទុក្ខរបស់អ្នកស្រី អៀង ធីរិទ្ធប្រឆាំងនឹង "សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់ លោក នួន ជា, លោក ខៀវ សំផន និងអ្នកស្រី អៀង ធីរិទ្ធ"របស់អង្គជំនុំជម្រះសាលាដំបូង**

---

<u>ដាក់ដោយ</u>៖

**សហមេធាវីរបស់ អៀង ធីរិទ្ធ**

លោក ផាត់ពៅស៊ាង

កញ្ញា Diana ELLI, QC

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល**

ឯកឧត្តម គង់ ស្រ៊ីម

ចៅក្រម Mottoo NOGUCHI

ចៅក្រម Agnieszka KLONOWIECKA-MILART

ចៅក្រម Chandra NIHAL JAYASINGHE

<u>ផ្ញើជូន</u>៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

PICH Ang
Elisabeth SIMONNEAU FORT

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 05 / 04 / 2011
ម៉ោង (Time/Heure): 08 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

---

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម ស៊ិន វិទ្ធ

ចៅក្រម យ៉ា ណារិន

ចៅក្រម ម៉ង់ មុន្នីចរិយា

ចៅក្រម Florence MUMBA

## I សេចក្តីផ្តើម

១. នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១, អង្គជំនុំជម្រះសាលាដំបូងបានចេញ "សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់លោកនួន ជា, លោក ខៀវ សំផន និង អ្នកស្រី អៀង ធីរិទ្ធ" (**សេចក្តីសម្រេចរងការជំទាស់តវ៉ា**)[1]។ នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១១ មេធាវីការពារក្តី អៀង ធីរិទ្ធ (**ជនជាប់ចោទ**) បានដាក់បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចនោះ (**បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី**)[2] ហើយដែលសហព្រះរាជអាជ្ញាបានឆ្លើយតបនៅថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១១ (**ចម្លើយតប**)[3]។ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាកំពូលបានជូនដំណឹងដល់មេធាវីការពារក្តីនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១១ថា: អង្គជំនុំជម្រះតុលាកំពូលនឹងមិនមានបំណងបើកសវនាការផ្ទាល់មាត់ទេ។ ហេតុដូច្នេះ មេធាវីការពារក្តីតទៅនេះត្រូវដាក់នូវចម្លើយតបរបស់ខ្លួន។

## II. សេចក្តីសន្និដ្ឋានតប

២. ចម្លើយតបបានចោទថា:"បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីគួរត្រូវបានបដិសេធចោលទាំងស្រុង ដោយសារថាជនជាប់ចោទខកខានមិនបានបង្ហាញឱ្យឃើញថាអង្គជំនុំជម្រះសាលាដំបូងពិតជាមានកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឡើយ[...]"[4]។ មេធាវីការពារក្តីស្នើសុំឱ្យពិចារណាថា វិធាន ១០៤ និង វិធាន ១០៥នៃវិធានផ្ទៃក្នុងបានបញ្ជាក់ថា:យុត្តាធិការទៅលើបណ្តឹងសាទុក្ខរបស់អង្គជំនុំជម្រះតុលាកំពូល គឺអាចឈរលើមូលដ្ឋាននៃកំហុសអង្គច្បាប់, កំហុសជាក់ស្តែងនៅ

---

[1] សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់លោកនួន ជា, លោក ខៀវ សំផន និង អ្នកស្រី អៀង ធីរិទ្ធ, ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ: E50 ។

[2] បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់លោកនួន ជា, លោក ខៀវ សំផន និង អ្នកស្រី អៀង ធីរិទ្ធ ដែលបានដាក់ក្នុងនាមជាម្ចាស់បណ្តឹងសាទុក្ខ អ្នកស្រី អៀង ធីរិទ្ធ, ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ: E50/2/1/1 ។

[3] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់អ្នកស្រី អៀង ធីរិទ្ធប្រឆាំងនឹង សេចក្តីសម្រេចលើសំណើសុំដោះលែងបន្ទាន់របស់លោកនួន ជា, លោក ខៀវ សំផន និង អ្នកស្រី អៀង ធីរិទ្ធ, ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១, ឯកសារលេខ: E50/2/1/1/1 ។

[4] កថាខណ្ឌទី ៣ នៃចម្លើយតបរបស់ កសព។

ក្នុងការអនុវត្តឆន្ទានុសិទ្ធិ និង កំហុសលើអង្គហេតុ។ បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីគឺបានផ្អែកទៅលើកំហុសអង្គច្បាប់ និងកំហុសលើអង្គហេតុ ហើយនិងអនុលោមតាមវិធាន ១០៥នៃវិធានផ្ទៃក្នុង ហេតុនេះហើយមេធាវីការពារក្តីមិនតម្រូវឲ្យបង្ហាញនូវកំហុសពិតប្រាកដនៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងតាមការចោទប្រកាន់នៅក្នុងចម្លើយរបស់ កសព នោះទេ។ ដោយសារតែ ចម្លើយតបនោះមិនបាននិយាយអំពីសារធាតុនៃមូលហេតុបណ្តឹងសាទុក្ខដែលបានលើកឡើងដោយមេធាវីការពារក្តីនោះ ដូច្នេះវាត្រូវតែបដិសេធចោល។

៣. មេធាវីការពារក្តីសូមស្នើឲ្យពិចារណាថាអំណះអំណាងភាគច្រើនដែលបានលើកឡើងនៅក្នុងចម្លើយតបរបស់ កសពនោះ ត្រូវបានដោះស្រាយយ៉ាងពេញលេញនៅក្នុងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី។ ប៉ុន្តែ មានចំណុចមួយដែលថា សហព្រះរាជអាជ្ញាបានលើកឡើងជាច្រើនលើកច្រើនសារដែលពាក់ព័ន្ធនឹងការចោទប្រកាន់ថា: "ជនជាប់ចោទបានខកខាន[...]មិនបានបង្ហាញអំពីកំហុសនៅក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងដែលនាំឲ្យមានព្យសនកម្មដល់ជនជាប់ចោទ"[5]។

៤. មេធាវីការពារក្តីយល់ឃើញថា ការឃុំខ្លួនខុសច្បាប់បណ្តាលឲ្យមានព្យសនកម្ម។

៥. មាត្រា ៩(៥)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) បានចែងថា: "ជនណាដែលទទួលរងគ្រោះនៃការចាប់ខ្លួន ឬឃុំខ្លួនដោយខុសច្បាប់ត្រូវតែមានសិទ្ធិក្នុងការទទួលបានសំណង"។ សិទ្ធិនេះមានជាស្វ័យប្រវត្តិ កាលណាព្យសនកម្មត្រូវបានសន្មត់។ លោក Stefan Trechsel បានលើកឡើងនៅក្នុងការអត្ថាអធិប្បាយរបស់គាត់អំពីអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស (ECHR) និង (ICCPR) ដែលបានជំទាស់យ៉ាងពិតប្រាកដនៅក្នុងការបកស្រាយមាត្រា ៥(៥)នៃ ECHR ថាវាស្រដៀងគ្នាទៅនឹងមាត្រា ៩(៥)នៃ ICCPR ហើយថា ផ្នែកនេះ "ត្រូវតែអានថា: ការសន្មត់តាមផ្លូវច្បាប់ថា: ការឃុំខ្លួនដោយខុសច្បាប់តែងតែបង្កឲ្យមានការខូចខាតទោះបីជាវាមិនមែនជា លក្ខណៈប្រាក់កាសក៏ដោយ"[6] ។

---

[5] កថាខណ្ឌទី ៣ នៃចម្លើយតបរបស់ កសព។ សូមពិនិត្យមើល កថាខណ្ឌទី ១១នៃចម្លើយតបនេះផងដែរ។

[6] Stefan Trechsel, សិទ្ធិមនុស្សនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ (២០០៥) ទំព័រ ៥០០ ។

III. សេចក្ដីសន្និដ្ឋាន

៦. សំរាប់ហេតុផលទាំងអស់នេះ មេធាវីការពារក្ដីសូមស្នើឲ្យពិចារណាថា: ព្យសនកម្មត្រូវបានបង្ហាញ និងសូមរក្សានូវអំណះអំណាងរបស់ខ្លួន ហើយនិង ស្នើសុំដាក់នៅក្នុងបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះរបស់មេធាវី | ទីកន្លែង | ហត្ថលេខា |
| --- | --- | --- | --- | --- |
| មេធាវីការពារក្ដី<br>អ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី៥ ខែមេសា<br>ឆ្នាំ២០១១ | លោកផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature and stamp: AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA] |